រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៩

# សេចក្តីសំរេច លេខ ៥១ សសរ

## ស្តីពីការផ្ទេរសិទ្ធិរដ្ឋមន្ត្រី

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-យោងតាមតំរូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ផ្ទេរសិទ្ធិជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទទួលបន្ទុកបន្ថែមជារដ្ឋមន្ត្រី នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជំនួសឯកឧត្តម**ហោ ណាំហុង** ដែលត្រូវបានអញ្ជើញទៅបំពេញបេសកកម្មនៅក្រៅប្រទេស ដោយគិតចាប់ពីថ្ងៃ ទី០៧ ខែ កក្កដា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៩ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និង ឯកឧត្តម **គាត ឈន់** ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★